ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា

លេខ:.........០០៥.......គ.ល.ក.ប្រក

# ប្រកាស
# ស្តីពី
# បែបបទ និងនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាល និងពិន័យអន្តរការណ៍ ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/១១២០/០៣១ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៦៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០២ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ស្តីពីការពិន័យអន្តរ-ការណ៍ចំពោះបទល្មើសទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
- យោងតាមការសម្រេចរបស់គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា នាសម័យប្រជុំលើកទី៥ អាណត្តិទី១ នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២២

អាសយដ្ឋាន : លេខ ៦-៨ មហាវិថីព្រះនរោត្តម, រាជធានីភ្នំពេញ កម្ពុជា
Address: No 6-8 Preah Norodom Blvd, Phnom Penh, Cambodia.

ទូរសព្ទ: (+៨៥៥)២៣ ៩០២ ០៩០
Phone: (+855)23 902 090

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះ កំណត់អំពី បែបបទ និងនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាលនិងពិន័យអន្តរការណ៍ ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម ក្នុងគោលបំណងជំរុញឱ្យកម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ កម្មសិទ្ធិករកាស៊ីណូ និង/ឬប្រតិបត្តិករល្បែងពាណិជ្ជកម្ម និងភាគីពាក់ព័ន្ធ អនុវត្តឱ្យស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ២ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអំពើល្មើសនឹងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្មដែលត្រូវដាក់ទណ្ឌកម្មរដ្ឋបាលនិងពិន័យអន្តរការណ៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## សមត្ថកិច្ច

**ប្រការ៣ .-**

ការដាក់ទណ្ឌកម្មរដ្ឋបាល និងពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម ជាសមត្ថកិច្ចរបស់ **គ.ល.ក.**។

ប្រធាន **គ.ល.ក.** អាចប្រគល់សិទ្ធិជូនអគ្គលេខាធិការ **គ.ល.ក.** ដើម្បីចេញលិខិតព្រមានជាលាយលក្ខណ៍អក្សរនិងពិន័យអន្តរការណ៍ ស្របតាមច្បាប់ និងនីតិវិធីជាធរមាន។

អគ្គលេខាធិការ **គ.ល.ក.** អាចអញ្ជើញបុគ្គលសង្ស័យប្រព្រឹត្តល្មើស មកឆ្លើយបំភ្លឺមុននឹងបន្តនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាលណាមួយ។

ការព្យួរ ឬការដកហូតអាជ្ញាបណ្ណត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ល.ក.**។ អគ្គលេខាធិការ **គ.ល.ក.** ត្រូវរៀបចំរបាយការណ៍ដោយភ្ជាប់ជាមួយនូវឯកសារ ឬភស្តុតាងនៃអំពើល្មើស ដើម្បីដាក់ជូនប្រធាន **គ.ល.ក.** ពិនិត្យសម្រេច។

## ជំពូកទី៣

## បែបបទ និងនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាល ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម

### ផ្នែកទី១

### ប្រភេទនៃទណ្ឌកម្មរដ្ឋបាល

**ប្រការ៤ .-**

ទណ្ឌកម្មរដ្ឋបាលរួមមាន ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរអាជ្ញាបណ្ណ និងការដកហូតអាជ្ញាបណ្ណ។

### ផ្នែកទី២

### ការព្រមានជាលាយលក្ខណ៍អក្សរ

**ប្រការ៥ .-**

កម្មសិទ្ធិករកាស៊ីណូ និង/ឬប្រតិបត្តិករកាស៊ីណូ ត្រូវទទួលរងការព្រមានជាលាយលក្ខណ៍អក្សរក្នុងករណីបានប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

- ប្រព្រឹត្តផ្ទុយនឹងការណែនាំរបស់ គ.ល.ក. ដូចមានចែងក្នុងមាត្រា៥៩ នៃច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
- ការផ្សាយពាណិជ្ជកម្មអំពីល្បែងពាណិជ្ជកម្មដែលគ្មានការយល់ព្រមពី គ.ល.ក. ដូចមានចែងក្នុងមាត្រា៧៣ នៃច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
- ដំណើរការល្បែងសាកល្បងសម្រាប់ហ្វឹកហាត់និងណែនាំដល់បុគ្គលិក ឬធ្វើតេស្តម៉ាស៊ីនល្បែង ឬឧបករណ៍និង/ឬកម្មវិធីល្បែងដោយគ្មានការឯកភាពជាមុនពី **គ.ល.ក.** ដូចមានចែងក្នុងមាត្រា៧៩ នៃច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម។

**ប្រការ៦ ._**

ប្រតិបត្តិករល្បែងភ្នាល់ ប្រតិបត្តិករល្បែងផ្សងសំណាង និងប្រតិបត្តិករល្បែងពាណិជ្ជកម្មដទៃទៀត ត្រូវទទួលរងការព្រមានជាលាយលក្ខណ៍អក្សរក្នុងករណីបានប្រព្រឹត្តអំពើណាមួយខាងក្រោម៖

- មិនអនុវត្តតាមលក្ខខណ្ឌនៃអាជ្ញាបណ្ណល្បែងភ្នាល់ ឬអាជ្ញាបណ្ណល្បែងផ្សងសំណាង ឬអាជ្ញាបណ្ណល្បែងពាណិជ្ជកម្មដទៃទៀត
- មិនអនុវត្តតាមមាត្រា៧៣ នៃច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
- ដំណើរការល្បែងសាកល្បងសម្រាប់ហ្វឹកហាត់ ឬណែនាំដល់បុគ្គលិក ឬធ្វើតេស្តម៉ាស៊ីនល្បែង ឬឧបករណ៍និង/ឬកម្មវិធីល្បែងដោយពុំមានការឯកភាពជាមុនពី **គ.ល.ក.**
- មិនអនុវត្តតាមការណែនាំរបស់ **គ.ល.ក.** និងលក្ខខណ្ឌតម្រូវផ្សេងទៀតដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ៧ ._**

ភាគីពាក់ព័ន្ធ ត្រូវទទួលរងការព្រមានជាលាយលក្ខណ៍អក្សរ ក្នុងករណីបានប្រព្រឹត្តអំពើណាមួយខាងក្រោម៖

- មិនអនុវត្តតាមលក្ខខណ្ឌនៃអាជ្ញាបណ្ណបុគ្គលិកពិសេស ឬអាជ្ញាបណ្ណអ្នកជំរុញល្បែង ឬអាជ្ញាបណ្ណអ្នកផលិត អ្នកដំឡើង អ្នកនាំចូល អ្នកលក់ និង/ឬអ្នកចែកចាយឧបករណ៍និង/ឬកម្មវិធីល្បែង
- ផ្សាយពាណិជ្ជកម្មអំពីផលិតផល ឬសេវាពាក់ព័ន្ធនឹងវិស័យល្បែងពាណិជ្ជកម្មដោយពុំមានការអនុញ្ញាតនិងយល់ព្រមពី **គ.ល.ក.**
- មិនអនុវត្តតាមការណែនាំរបស់ **គ.ល.ក.** និងលក្ខខណ្ឌតម្រូវផ្សេងទៀតដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ផ្នែកទី៣

## ការព្យួរអាជ្ញាបណ្ណ

**ប្រការ៨ ._**

កម្មសិទ្ធិករកាស៊ីណូ និង/ឬប្រតិបត្តិករកាស៊ីណូ ត្រូវទទួលរងការព្យួរអាជ្ញាបណ្ណ ក្នុងករណីបានប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

- បុគ្គលិកពិសេស ប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី២ នៃមាត្រា៥៣ នៃច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម

– ប្រតិបត្តិករកាស៊ីណូប្រព្រឹត្តល្មើសនឹងមាត្រា៨០ នៃច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
– ប្រតិបត្តិករល្បែងពាណិជ្ជកម្មបានប្រព្រឹត្តល្មើសនឹងមាត្រា៥៤ មាត្រា៥៥ មាត្រា៥៦ មាត្រា៥៧ មាត្រា៥៨ ចំណុច ក និង ខ នៃកថាខណ្ឌទី១ នៃមាត្រា៦០ មាត្រា៧៦ ឬមាត្រា៧៧ នៃច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
– ប្រតិបត្តិករកាស៊ីណូប្រព្រឹត្តល្មើសដូចមានចែងក្នុងកថាខណ្ឌទី៥ នៃមាត្រា៦៣ នៃច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
– ប្រតិបត្តិករកាស៊ីណូមិនគោរពតាមការព្រមានជាលាយលក្ខណ៍អក្សររបស់ **គ.ល.ក.**។

**ប្រការ៩ .-**

ប្រតិបត្តិករល្បែងភ្នាល់ ប្រតិបត្តិករល្បែងផ្សងសំណាង ប្រតិបត្តិករល្បែងពាណិជ្ជកម្មដទៃទៀត និងភាគីពាក់ព័ន្ធ ត្រូវទទួលរងការព្យួរអាជ្ញាបណ្ណក្នុងករណីបានប្រព្រឹត្តអំពើណាមួយខាងក្រោម៖

– មិនអនុវត្តតាមការព្រមានជាលាយលក្ខណ៍អក្សររបស់ **គ.ល.ក.**
– មិនបង់ប្រាក់ពិន័យអន្តរការណ៍តាមការកំណត់របស់ **គ.ល.ក.** ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
– បានប្រព្រឹត្តល្មើសដូចមានចែងក្នុងចំណុច ខ នៃមាត្រា៣៦ នៃអនុក្រឹត្យលេខ ១០២ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ស្តីពីការពិន័យអន្តរការណ៍ចំពោះបទល្មើសទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម។

## ផ្នែកទី៤
## ការដកហូតអាជ្ញាបណ្ណ

**ប្រការ១០ .-**

កម្មសិទ្ធិករកាស៊ីណូ និង/ឬប្រតិបត្តិករកាស៊ីណូ ត្រូវទទួលរងការដកហូតអាជ្ញាបណ្ណ ក្នុងករណីបានប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

– ផ្ទេរអាជ្ញាបណ្ណល្បែងពាណិជ្ជកម្ម ឬប្រតិបត្តិការល្បែងពាណិជ្ជកម្មទាំងស្រុង ឬមួយផ្នែកតាមវិធី ឬរូបភាពណាក៏ដោយ ដោយមិនមានការអនុញ្ញាតពី គ.ល.ក.
– មិនបង់កាតព្វកិច្ចពន្ធដារ មិនបង់ចំណូលកាតព្វកិច្ចពីល្បែង កម្រៃអាជ្ញាបណ្ណ ឬកាតព្វកិច្ចហិរញ្ញវត្ថុដទៃទៀតក្នុងចំនួននិងតាមពេលកំណត់ ដូចមានចែងក្នុងមាត្រា៨២ មាត្រា៨៣ និងមាត្រា៨៤ នៃច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
– ប្រព្រឹត្តល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា៦៥ នៃច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
– បន្តប្រព្រឹត្ត ឬមិនកែលម្អអំពើល្មើសធ្ងន់ធ្ងរនឹងលក្ខខណ្ឌអាជ្ញាបណ្ណ
– នៅតែបន្តប្រព្រឹត្តអំពើល្មើសដែលមានចែងក្នុងមាត្រា៨៩ នៃច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
– នៅតែធ្វើប្រតិបត្តិការកាស៊ីណូក្នុងអំឡុងពេលព្យួរអាជ្ញាបណ្ណ។

**ប្រការ១១ ._**

ប្រតិបត្តិករល្បែងភ្នាល់ ប្រតិបត្តិករល្បែងផ្សងសំណាង ប្រតិបត្តិករល្បែងពាណិជ្ជកម្មដទៃទៀត និងភាគី-ពាក់ព័ន្ធ ត្រូវទទួលរងការដកហូតអាជ្ញាបណ្ណ ក្នុងករណីបានប្រព្រឹត្តអំពើណាមួយខាងក្រោម៖

- មិនបំពេញកាតព្វកិច្ចហិរញ្ញវត្ថុតាមការកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- មិនកែតម្រូវ ឬបន្តប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរនឹងលក្ខខណ្ឌនៃអាជ្ញាបណ្ណ
- មិនអនុវត្តតាមសេចក្តីសម្រេចស្តីពីការព្យួរអាជ្ញាបណ្ណ ដូចមានចែងក្នុងប្រការ៨ នៃប្រកាសនេះ។

## ផ្នែកទី៥
## នីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាល

**ប្រការ១២ ._**

អគ្គលេខាធិការ **គ.ល.ក.** អាចចេញលិខិតព្រមានជាលាយលក្ខណ៍អក្សរដោយបញ្ជាក់អំពីកំហុសឆ្គង និងការកែតម្រូវ ដោយកំណត់ពេលវេលាជាក់លាក់ដល់កម្មសិទ្ធិករកាស៊ីណូ និង/ឬប្រតិបត្តិករ កាស៊ីណូប្រតិបត្តិករល្បែងភ្នាល់ ប្រតិបត្តិករល្បែងផ្សងសំណាង ប្រតិបត្តិករល្បែងពាណិជ្ជកម្មដទៃទៀត និងភាគីពាក់ព័ន្ធ ក្រោយពីពិនិត្យឃើញថា បានប្រព្រឹត្តអំពើល្មើសណាមួយដូចបានចែងក្នុងប្រការ៥ ប្រការ៦ និងប្រការ៧ នៃប្រកាសនេះ។

**ប្រការ១៣ ._**

ប្រធាន **គ.ល.ក.** អាចចេញសេចក្តីសម្រេចព្យួរអាជ្ញាបណ្ណ ដោយបញ្ជាក់អំពីមូលហេតុនៃការព្យួរកាតព្វកិច្ចដែលត្រូវអនុវត្ត និងរយៈពេលនៃការព្យួរ តាមសំណើរបស់អគ្គលេខាធិការ **គ.ល.ក.** ក្រោយពីពិនិត្យឃើញថា កម្មសិទ្ធិករកាស៊ីណូនិង/ឬប្រតិបត្តិករកាស៊ីណូ ប្រតិបត្តិករល្បែងភ្នាល់ ប្រតិបត្តិករល្បែងផ្សងសំណាង ប្រតិបត្តិករល្បែងពាណិជ្ជកម្មដទៃទៀត ឬភាគីពាក់ព័ន្ធ បានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងប្រការ៨ និងប្រការ៩ នៃប្រកាសនេះ។

បន្ទាប់ពីទទួលបានសេចក្តីសម្រេចដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើកម្មសិទ្ធិករកាស៊ីណូនិង/ឬប្រតិបត្តិករកាស៊ីណូ ប្រតិបត្តិករល្បែងភ្នាល់ ប្រតិបត្តិករល្បែងផ្សងសំណាង ប្រតិបត្តិករល្បែងពាណិជ្ជកម្មដទៃទៀត ឬភាគីពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្តីសម្រេចព្យួរអាជ្ញាបណ្ណ រហូតដល់មានការសម្រេចជាថ្មីពី **គ.ល.ក.**។

**ប្រការ១៤ ._**

ប្រធាន **គ.ល.ក.** អាចចេញសេចក្តីសម្រេចដកហូតអាជ្ញាបណ្ណ ដោយបញ្ជាក់អំពីមូលហេតុនៃការដកហូតនោះ តាមសំណើរបស់អគ្គលេខាធិការ **គ.ល.ក.** ក្រោយពីពិនិត្យឃើញថា កម្មសិទ្ធិករកាស៊ីណូនិង/ឬប្រតិបត្តិករកាស៊ីណូ ប្រតិបត្តិករល្បែងភ្នាល់ ប្រតិបត្តិករល្បែងផ្សងសំណាង ប្រតិបត្តិករល្បែងពាណិជ្ជកម្មដទៃទៀត ឬភាគីពាក់ព័ន្ធ បានប្រព្រឹត្តអំពើល្មើសណាមួយដូចចែងក្នុងប្រការ១០ និងប្រការ១១ នៃប្រកាសនេះ។

**ប្រការ១៥ ._**

កម្មសិទ្ធិករកាស៊ីណូ និង/ឬប្រតិបត្តិករកាស៊ីណូ ប្រតិបត្តិករល្បែងភ្នាល់ ប្រតិបត្តិករល្បែងផ្សងសំណាង ប្រតិបត្តិករល្បែងពាណិជ្ជកម្មដទៃទៀត ឬភាគីពាក់ព័ន្ធ ដែលមិនសុខចិត្តនឹងការព្រមានជាលាយលក្ខណ៍អក្សរ

របស់អគ្គលេខាធិការ **គ.ល.ក.** មានសិទ្ធិប្តឹងតវ៉ាមកប្រធាន **គ.ល.ក.** នៅអគ្គលេខាធិការដ្ឋាននៃ **គ.ល.ក.** ក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានលិខិតព្រមានជាលាយលក្ខណ៍អក្សរ។

ប្រធាន **គ.ល.ក.** ត្រូវចេញសេចក្តីសម្រេចលើពាក្យបណ្តឹងតវ៉ាលើការព្រមានជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹងតវ៉ា។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលរបស់ប្រធាន **គ.ល.ក.** មានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ច ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេចនេះ។

## ជំពូកទី៤
## បែបបទនិងនីតិវិធីនៃការពិន័យអន្តរការណ៍
## ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម

**ប្រការ១៦ ._**

អគ្គលេខាធិការ **គ.ល.ក.** ត្រូវចេញលិខិតបង្គាប់ឱ្យបុគ្គលល្មើសបង់ប្រាក់ពិន័យអន្តរការណ៍ តាមការកំណត់ក្នុងអនុក្រឹត្យលេខ ១០២ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ស្តីពីការពិន័យអន្តរការណ៍ចំពោះបទល្មើសទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម។

**ប្រការ១៧ ._**

បុគ្គលល្មើស ត្រូវមកបង់ប្រាក់ពិន័យអន្តរការណ៍ តាមការកំណត់ក្នុងលិខិតបង្គាប់ឱ្យបង់ពិន័យអន្តរការណ៍ នៅអគ្គលេខាធិការដ្ឋាននៃ **គ.ល.ក.** ឬបង់ចូលគណនីរបស់ **គ.ល.ក.** នៅធនាគារកាណាឌីយ៉ា ដែលមានគណនីលេខ 001-0005425382 ហើយត្រូវផ្តល់បង្កាន់ដៃបង់ប្រាក់ច្បាប់ដើម មកអគ្គលេខាធិការដ្ឋាននៃ **គ.ល.ក.** ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានបង្កាន់ដៃបង់ប្រាក់នោះ។

រាល់ការទទួលប្រាក់ពិន័យអន្តរការណ៍ជាសាច់ប្រាក់ ឬមូលប្បទានបត្រ ត្រូវមានបង្កាន់ដៃបង់ប្រាក់ពិន័យអន្តរការណ៍តាមទម្រង់ដែលកំណត់ដោយអគ្គលេខាធិការដ្ឋាននៃ **គ.ល.ក.**។

ក្នុងករណីខកខានមិនបានបង់ប្រាក់ពិន័យតាមកាលកំណត់ បុគ្គលល្មើសត្រូវទទួលពិន័យអន្តរការណ៍ស្របតាមមាត្រា៣៥ នៃអនុក្រឹត្យលេខ ១០២ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ស្តីពីការពិន័យអន្តរការណ៍ចំពោះបទល្មើសទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម។

ក្នុងករណីមិនសុខចិត្តនឹងសេចក្តីសម្រេចស្តីពីការពិន័យអន្តរការណ៍ បុគ្គលល្មើសមានសិទ្ធិប្តឹងទៅប្រធាន **គ.ល.ក.** ស្របតាមនីតិវិធីដូចមានចែងក្នុងមាត្រា៣៧ នៃអនុក្រឹត្យលេខ ១០២ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ស្តីពីការពិន័យអន្តរការណ៍ចំពោះបទល្មើសទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ១៨ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៩ ._**

អគ្គលេខាធិការ អគ្គលេខាធិការរង **គ.ល.ក.** ប្រធាននាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋាននៃ **គ.ល.ក.** និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៨រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់សមាសភាពនៃ **គ.ល.ក.**

  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៩ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ